ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ក្របខ័ណ្ឌយុទ្ធសាស្ត្រ

## ស្តីពី

# ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ខែ មករា ឆ្នាំ ២០០៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

# ក្របខ័ណ្ឌយុទ្ធសាស្ត្រ

# ស្តីពី

# ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

**ខែ មករា ឆ្នាំ ២០០៦**

# អារម្ភកថា

«ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍»នេះ គឺជាឯកសារគោលនយោបាយរបស់ រាជរដ្ឋាភិបាល ។ ក្របខ័ណ្ឌយុទ្ធសាស្ត្របានគូសបញ្ជាក់អំពីតួនាទី និងភារកិច្ចនៃបណ្តាក្រសួងនិងស្ថាប័ន ដែលពាក់ព័ន្ធនឹងការកៀរគរធនធាន និងការគ្រប់គ្រងជំនួយ ស្របតាមខ្លឹមសារនៃច្បាប់ និងលិខិតបទដ្ឋានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ។ លើសពីនេះ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះក៏បានកំណត់អំពីគោលដៅ និងបណ្តាគោលការណ៍ សំខាន់ៗជាមូលដ្ឋានសំរាប់ណែនាំការគ្រប់គ្រងកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍ សំដៅបង្កើនប្រសិទ្ធភាពជំនួយ ព្រមទាំងការរៀបចំកម្មវិធីជាតិសំរាប់អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ។

រាជរដ្ឋាភិបាលជំរុញ និងលើកទឹកចិត្តអោយដៃគូអភិវឌ្ឍន៍ធ្វើការជាមួយ**គណៈកម្មាធិការនីតិសម្បទាននិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ ក.អ.ក)** ដែលជា «ចំណុចប្រមូលផ្តុំ» របស់រាជរដ្ឋាភិបាលសម្រាប់កៀរគរ និងសម្របសម្រួលជំនួយអភិវឌ្ឍន៍ផ្លូវការ ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយ។

«ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍»នេះ ត្រូវបានអនុមតិដោយគណៈរដ្ឋមន្ត្រី នៅក្នុងអង្គប្រជុំពេញ នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ។ រាជរដ្ឋាភិបាលចាត់ទុកថា នេះការងារអាទិភាពខ្ពស់មួយ ដែលភាគី ពាក់ព័ន្ធទាំងអស់អនុវត្តន៍ឱ្យបានត្រឹមត្រូវ តាមគោលការណ៍នៃក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ដែលបានឆ្លុះបញ្ចាំងអំពី គោលការណ៍ទាំងឡាយនៃ «សេចក្តីប្រកាសទីក្រុងរ៉ូម» និង «សេចក្តីប្រកាសទីក្រុងប៉ារីស» ស្តីពីប្រសិទ្ធភាពនៃជំនួយ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០០៦

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ប្រធានគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍

# មាតិកា


| | | |
|---|---|---|
| I - | សេចក្ដីផ្ដើម | ១ |
| II - | «ចំណុចប្រមូលផ្ដុំ»របស់រាជរដ្ឋាភិបាលសម្រាប់កៀរគរ និងសម្របសម្រួល ជំនួយបរទេស | ២ |
| III- | ស្ថានភាពបច្ចុប្បន្ន និងគំនិតផ្ដួចផ្ដើមថ្មីៗសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ | ៥ |
| IV- | គោលដៅ និងគោលការណ៍មូលដ្ឋាននៃយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ | ៩ |
| V- | កម្មវិធីជាតិសម្រាប់អនុវត្តយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ | ១១ |

ឧបសម្ព័ន្ធ: អនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ១៤៧អនក្រ. បកចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# ក្របខ័ណ្ឌយុទ្ធសាស្ត្រ
# ស្តីពី
# ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

## I- សេចក្តីផ្តើម

១- ឯកសារ «ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍» បានធ្វើការអះអាងសារជាថ្មីម្តងទៀត អំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងភាពជាម្ចាស់ និងភាពដឹកនាំនៃការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ឯកសារនេះនឹងគូសបញ្ជាក់អំពីគោលនយោបាយជាយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធនឹងទិដ្ឋភាពខាងស្ថាប័ន និងខាងប្រតិបត្តិការនៃការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ឯកសារនេះនឹង ÷

ក- ពិពណ៌នាអំពីតួនាទី និងភារកិច្ចនៃស្ថាប័នដែលជា«ចំណុចប្រមូលផ្តុំ»របស់រាជរដ្ឋាភិបាល ក្នុងការកៀរគរ និងសម្របសម្រួលជំនួយបរទេស ។

ខ- ពិពណ៌នាអំពីស្ថានភាពបច្ចុប្បន្ន និងគំនិតផ្តួចផ្តើមថ្មីៗរបស់រាជរដ្ឋាភិបាលនិងសហគមន៍អន្តរជាតិ ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

គ- កំណត់គោលដៅ និងគោលការណ៍សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍ ។

ឃ- រៀបរាប់ដោយសង្ខេប អំពីកម្មវិធីជាតិសម្រាប់អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ។

២- រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ថា ការប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវជំនួយអភិវឌ្ឍន៍ផ្លូវការ ជាកត្តាគន្លឹះក្នុងការសម្រេចគោលដៅនៃ «យុទ្ធសាស្ត្រចតុកោណ» និងបណ្តាគោលដៅអាទិភាពដែលមាននៅក្នុង «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ» សំដៅកាត់បន្ថយភាពក្រីក្រ និងសម្រេចឱ្យបាននូវ «គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា» ។ ដើម្បីសម្រេចឱ្យបាននូវគោលដៅទាំងនេះ រាជរដ្ឋាភិបាលចាត់ទុកថា ការបង្កើនប្រសិទ្ធភាពជំនួយគឺជាអាទិភាពចម្បងមួយ ដើម្បីទាញយកគុណប្រយោជន៍ពីការប្រើប្រាស់ជំនួយទាំងនេះមកបំរើប្រជាជនកម្ពុជា ។

៣- រាជរដ្ឋាភិបាលបានយល់ច្បាស់អំពីបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលដៅទាំងនេះ ។ ទន្ទឹមនឹងលទ្ធផលជាផ្លែផ្កាកន្លងមក បណ្តាក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាលដែលមានភារៈកិច្ចអនុវត្តគម្រោងអភិវឌ្ឍន៍ នៅមានកិច្ចការជាច្រើនទៀតដែលត្រូវអនុវត្តបន្ត ដើម្បីបង្កើនប្រសិទ្ធភាពជំនួយបន្ថែមទៀត ។ រីឯដៃគូអភិវឌ្ឍន៍ត្រូវបន្តធ្វើសុខដុមនីយកម្មការអនុវត្តន៍របស់ខ្លួន ដើម្បីកាត់បន្ថយបន្ទុកមកលើរាជរដ្ឋាភិបាល ដែលសមត្ថភាពនៅមានកម្រិត និងដើម្បីធានាឱ្យមានតម្លាភាព ក្នុងការប្រើប្រាស់ជំនួយ ដែលបានផ្តល់មកឱ្យកម្ពុជា ។ រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណ ចំពោះការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ (ទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល) ហើយសង្ឃឹមថា ដៃគូអភិវឌ្ឍន៍នឹង

បន្តផ្តល់ការគាំទ្របន្ថែមទៀត មករាជរដ្ឋាភិបាលក្នុង កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ ។ ជាក់ស្តែង ក្នុងរយៈកាលបីឆ្នាំចុងក្រោយនេះ ដៃគូអភិវឌ្ឍន៍បានរាយការណ៍ថា បានផ្តល់ជំនួយប្រមាណ៥០០លានដុល្លាអាមេរិកក្នុងមួយឆ្នាំ មកឱ្យកម្ពុជា ។ សមាសភាគនៃជំនួយក៏មានការប្រែប្រួលជាច្រើន រវាងជំនួយឥតសំណងនិងកម្ចីសម្បទាន ។ ធៀបនឹងជំនួយអភិវឌ្ឍន៍ផ្លូវការសរុប កម្ចីសម្បទានបានកើនឡើងពី១៦,៨% ក្នុងឆ្នាំ១៩៩៩ មក៣៤,៥%ក្នុងឆ្នាំ២០០២ និង៣០,៩%ក្នុងឆ្នាំ២០០៣ ហើយកើនដល់៣៤,៣%ក្នុងឆ្នាំ ២០០៤ ។ ការកើនឡើងនៃកម្ចីអាចមានផលប៉ះពាល់ដល់ថវិការជាតិនាពេលអនាគត ដោយរាជរដ្ឋាភិបាលត្រូវមានកាតព្វកិច្ចសងបំណុលនិងការប្រាក់ ។

## II - «ចំណុចប្រមូលផ្តុំ» របស់រាជរដ្ឋាភិបាលសំរាប់កៀរគរ និងសម្របសម្រួលជំនួយបរទេស

៤- គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ទ/ក.អ.ក) គឺជាស្ថាប័នស្នូលរបស់រាជរដ្ឋាភិបាល សម្រាប់កៀរគរជំនួយអភិវឌ្ឍន៍ផ្លូវការ ធ្វើការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ (រួមមានដៃគូអភិវឌ្ឍន៍ទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល) និងសម្របសម្រួលជាមួយក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល ក្នុងការតម្រង់ទិសបែងចែក និងប្រើប្រាស់ជំនួយ ។

៥- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានគណៈកម្មាធិការពីរ គឺ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា (គ.ជ.ទ) និងគណៈកម្មាធិការវិនិយោគកម្ពុជា (គ.វិ.ក) ។ សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា និងគណៈកម្មាធិការវិនិយោគកម្ពុជា មានកំណត់នៅក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ១៤៧អនក្រ.បកចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ ដោយឡែក តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា មានចែងនៅត្រង់មាត្រា១៣ ១៤ ១៥ និង១៦ នៃអនុក្រឹត្យលេខ១៤៧អនក្រ.បកចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ (សូមពិនិត្យមើលឧបសម្ព័ន្ធ) ។

៦- អនុលោមតាមមាត្រា១៣ នៃអនុក្រឹត្យលេខ១៤៧អនក្រ.បកចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៅក្នុងកិច្ចការវិនិយោគសាធារណៈ មានដូចតទៅ÷

- ក- ធ្វើជា «ចំណុចប្រមូលផ្តុំ» និងជា «ច្រកចេញ-ចូលតែមួយ» ក្នុងទំនាក់ទំនងរវាងរាជរដ្ឋាភិបាលជាមួយនឹងប្រទេស អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលផ្តល់ជំនួយដល់កម្ពុជា និងជា «ចំណុចប្រមូលផ្តុំ» និងជា «ច្រកចេញ-ចូលតែមួយ» ក្នុងទំនាក់ទំនងរវាងក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលការទទួលជំនួយ និង/ឬការបែងចែកជំនួយ ។
- ខ- តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាល ជាមួយនឹងអ្នកផ្តល់ជំនួយទ្វេភាគី ពហុភាគី និង/ឬបែងចែកជំនួយ ។

គ- សហការជាមួយបណ្ដាក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដឹកនាំការរៀបចំឯកសារចាំបាច់នានា សម្រាប់កិច្ចប្រជុំអន្តរជាតិសម្រាប់កសាងប្រទេសកម្ពុជាឡើងវិញ ដូចជា «ក្រុមពិគ្រោះយោបល់សម្រាប់កម្ពុជា» ជាដើម ។

៧- មាត្រា១៤នៃអនុក្រឹត្យលេខ១៤៧អនក្រ.បកចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ បានកំណត់អំពីការបែងចែកតួនាទី និងភារកិច្ចរវាងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបណ្ដាក្រសួងនិងស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ដូចតទៅ ÷

ក- «ក.អ.ក» ជាអ្នកសម្របសម្រួល ក្នុងការលើកទស្សនទានជាយុទ្ធសាស្ត្រនិងគោលនយោបាយនៃកិច្ចការវិនិយោគសាធារណៈ ព្រមទាំងជាអ្នកសម្របសម្រួលក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី និងគំរោងវិនិយោគសាធារណៈ សំរាប់រយៈពេលមធ្យមនិងរយៈពេលមួយឆ្នាំ ។

ខ- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាច្រកទ្វារការទូតផ្លូវការ ។

គ. ក្រសួងផែនការ ដោយសហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ជាអ្នករៀបចំ និងតាមដានការអនុវត្តន៍ផែនការ៥ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ ។

ឃ- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នករៀបចំការប៉ាន់ស្មានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ជាអ្នករៀបចំថវិកាសម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ និងជាអ្នកត្រួតពិនិត្យការធ្វើវិភាជន៍ហិរញ្ញប្បទាន ។

ង- ក្រសួងជំនាញជាអ្នករៀបចំកម្មវិធីនិងគម្រោងវិនិយោគសាធារណៈតាមផ្នែក ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ និងជាមួយ «ក.អ.ក» ព្រមទាំងជាអ្នកអនុវត្តកម្មវិធី និងគម្រោងវិនិយោគសាធារណៈតាមផ្នែក ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ខ្លួន ។

៨- មាត្រា១៥ និងមាត្រា១៦ នៃអនុក្រឹត្យលេខ១៤៧អនក្រ.បក បានកំណត់អំពីរបៀបរបបធ្វើការងារ ដោយក្រសួងនិងស្ថាប័នត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនខាងវិនិយោគសាធារណៈ ដោយត្រូវសម្របសម្រួលការងារជាមួយគ្នា តាមរយៈយន្តការ «ច្រកចេញ-ចូលតែមួយ» ។ រីឯទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងនិងស្ថាប័ន ត្រូវតាមដានការអនុវត្តកម្មវិធីនិងគម្រោងនានាស្របតាមសមត្ថកិច្ចរៀងៗខ្លួន ដោយសម្របសម្រួលការងារជាមួយគ្នា តាមរយៈយន្តការ «ច្រកចេញ-ចូលតែមួយ» ។

៩- ចំពោះកម្មវិធីនិងគម្រោងអភិវឌ្ឍន៍ដែលផ្ដល់ហិរញ្ញប្បទានដោយកម្ចីពីដៃគូអភិវឌ្ឍន៍ទ្វេភាគីនិងពហុភាគី ÷

ក- គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ត្រូវមានភារកិច្ចក្នុងការធានាឱ្យកម្មវិធី និងគម្រោងទាំងនោះ ឆ្លើយតបទៅនឹងអាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ។

ខ- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវពិនិត្យសំណើ ដើម្បីធានាថាសំណើទាំងនោះគឺជាអាទិភាព ដែលត្រូវធ្វើហិរញ្ញប្បទានដោយកម្ចី ។ ទន្ទឹមនេះ ក៏ត្រូវអនុម័តលក្ខខ័ណ្ឌកម្ចី និងពិនិត្យផលប៉ះពាល់នៃកាតព្វកិច្ចសងបំណុលនិងការប្រាក់ នៅក្នុងក្របខ័ណ្ឌបំណុលសរុបរបស់រាជរដ្ឋាភិបាល និងការ

ជះឥទ្ធិពលរបស់វាទៅក្នុងថវិការជាតិប្រចាំឆ្នាំ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចីទាំងអស់ ហើយក៏ជាស្ថាប័នតម្កល់ទុកឯកសារកិច្ចព្រមព្រៀងកម្ចីទាំងនេះផងដែរ ។ លើសពីនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏ត្រូវរក្សាពតិមានថ្មីៗស្តីពីការប្រើប្រាស់កម្ចី និងចាត់វិធានការភ្លាមៗ ដើម្បីកាត់បន្ថយចំណាយលើការផាកពិន័យដែលមានចែងក្នុងកិច្ចព្រមព្រៀងកម្ចី ឱ្យបានជាអតិបរមា ។

គ- ក្រសួងនិងស្ថាប័នដែលអនុវត្តកម្មវិធីនិងគម្រោងក្នុងក្របខ័ណ្ឌកំចី ត្រូវទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធី និងគម្រោងទាំងនោះប្រកបដោយតម្លាភាព និងគណនេយ្យភាព ដើម្បីផ្តល់ផលប្រយោជន៍ឱ្យបានជាអតិបរមាជូនប្រជាជន ។

១០- រាជរដ្ឋាភិបាលទទួលស្គាល់នូវបញ្ហាប្រឈមខាងសមត្ថភាព របស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា និងក្រសួងនិងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ក្នុងកិច្ចសម្របសម្រួលនិងគ្រប់គ្រងជំនួយ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលសូមស្នើឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់ យកចិត្តទុកដាក់ និងផ្តល់អាទិភាពខ្ពស់ដោយផ្តល់ការគាំទ្រសម្រាប់អភិវឌ្ឍសមត្ថភាព ទាំងខាងផ្នែកធនធានមនុស្ស និងទាំងខាងផ្នែកស្ថាប័នដើម្បីឱ្យ ក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាលមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងនិងសម្របសម្រួលជំនួយ សំដៅបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយ ។

១១- រាជរដ្ឋាភិបាលក៏កត់សំគាល់ឃើញផងដែរថា ទោះបីជារាជរដ្ឋាភិបាលបានកំណត់រួចហើយអំពីតួនាទីនិងភារកិច្ចរបស់ក្រសួងនិងស្ថាប័នក្នុងការគ្រប់គ្រងនិងសម្របសម្រួលជំនួយ ក្នុងព្រះរាជក្រឹត្យ និងអនុក្រឹត្យដែលមានជាធរមានក៏ដោយ ក៏ការអនុវត្តន៍រហូតមកដល់បច្ចុប្បន្ននៅមានការខ្វះចន្លោះនៅឡើយ ។ ប្រការដែលដៃគូអភិវឌ្ឍន៍មួយចំនួនបានចុះហត្ថលេខាព្រមព្រៀងផ្តល់ជំនួយដោយផ្ទាល់ជាមួយក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាល ដោយគ្មានការសម្របសម្រួលគ្នាជាមុនជាមួយគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ដែលជា «ចំណុចប្រមូលផ្តុំ» របស់រាជរដ្ឋាភិបាលសម្រាប់កិច្ចការទាំងនេះ គឺជាបញ្ហាមួយដែលប៉ះពាល់ដល់ កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង ការសម្របសម្រួល ការបែងចែកនិងការប្រើប្រាស់ជំនួយឱ្យមានប្រសិទ្ធភាព ។ រាជរដ្ឋាភិបាលចាត់ទុកថា ការអនុវត្តន៍ឱ្យបានត្រឹមត្រូវតាមស្មារតីនៃច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ គឺជាការងារអាទិភាពបន្ទាន់មួយ ។

១២- ដើម្បីបន្តពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ក៏ដូចជាក្រសួង និងស្ថាប័ននានា រាជរដ្ឋាភិបាលនឹងពន្លឿនដំណើរការរៀបចំដើម្បីឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានក្របខ័ណ្ឌ និងបុគ្គលិកផ្ទាល់ ព្រមទាំងមានថវិការបស់ខ្លួន ដូចបណ្តាក្រសួងដទៃទៀត ។ ប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាមសមិទ្ធផល នឹងត្រូវដាក់ឱ្យអនុវត្ត ដើម្បីពង្រឹងសមត្ថភាពរបស់មន្ត្រីនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ។ ចំណែកក្រសួងនិងស្ថាប័នដទៃទៀត ក៏ត្រូវរៀបចំ «ចំណុចប្រមូលផ្តុំ» របស់ខ្លួន សម្រាប់

ធ្វើជាសមភាគីជាមួយនឹងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ក្នុងកិច្ចការសម្របសម្រួលជំនួយដែរ ។

## III - ស្ថានភាពបច្ចុប្បន្ន និងគំនិតផ្តួចផ្តើមសំរាប់ពង្រឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

១៣- ក្នុងបណ្តាឆ្នាំកន្លងមកនេះ ការគ្រប់គ្រងនិងសម្របសម្រួលជំនួយនៅកម្ពុជាបានវិវត្តឥតឈប់ឈរ ដើម្បីឆ្លើយតបនឹងកំណើននៃលំហូរជំនួយបរទេស និងចំនួនកើនឡើងជាលំដាប់នៃប្រតិបត្តិករជាតិ និងអន្តរជាតិ ព្រមទាំងសកម្មភាពអភិវឌ្ឍន៍ដែលមានទិដ្ឋភាពកាន់តែស្មុគ្រស្មាញឡើង និងមានភាពប្រទាក់ក្រឡាគ្នាជាអន្តរវិស័យ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានបង្កើតយន្តការខាងផ្នែកស្ថាប័ន និងការគ្រប់គ្រងមួយចំនួនសម្រាប់គ្រប់គ្រង និងសម្របសម្រួលជំនួយបរទេស តាមរយៈគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

១៤- ទោះបីមានវឌ្ឍនភាពជាដុំកំភួនក្នុងកិច្ចការនេះក៏ដោយ ក៏ជំនួយអភិវឌ្ឍន៍ផ្លូវការមួយផ្នែកធំមិនបានឆ្លងកាត់ដំណើរការនៃថវិការដ្ឋឡើយ ដោយសារដៃគូអភិវឌ្ឍន៍មួយចំនួនបានធ្វើហិរញ្ញប្បទានត្រង់ និងដោយផ្ទាល់សម្រាប់អនុវត្តគម្រោងនិងកម្មវិធីរបស់ខ្លួន ។ ស្ថានភាពនេះបានប៉ះពាល់ដល់ភាពធ្វើជាម្ចាស់របស់ស្ថាប័ននៃរាជរដ្ឋាភិបាលទៅលើគម្រោងនិងកម្មវិធីអភិវឌ្ឍន៍មួយចំនួន និងបានជះឥទ្ធិពលដល់ការសម្របសម្រួលជំនួយ នៅតាមវិស័យនានា ព្រមទាំងការពង្រឹងស្ថាប័នផងដែរ ។ លើសពីនេះ ការប្រើប្រាស់ប្រព័ន្ធផ្សេងៗពីគ្នា ក្នុងការងារលទ្ធកម្ម និងសវនកម្ម និងប្រព័ន្ធត្រួតពិនិត្យនិងតាមដានរបស់ដៃគូអភិវឌ្ឍន៍ រួមជាមួយនឹងការបង្កើត «អង្គភាពអនុវត្តន៍គម្រោង» ដែលបាននិងកំពុងប្រើប្រាស់បុគ្គលិកជាតិ និងអន្តរជាតិតាមប្រព័ន្ធបៀវត្សរ៍ ដោយឡែក បានបង្កផលវិបាកជាច្រើន ដល់ការខិតខំពង្រឹងសមត្ថភាពខាងស្ថាប័នរបស់រាជរដ្ឋាភិបាល ។

១៥- ដើម្បីឆ្លើយតបនឹងបញ្ហាកង្វល់ទាំងនេះ រាជរដ្ឋាភិបាលបានបញ្ជាក់យ៉ាងច្បាស់ពីទស្សនទានរបស់ខ្លួន ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ នៅក្នុងឯកសារ «ក្របខ័ណ្ឌនៃភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់កម្ពុជាដើម្បីបង្កើនប្រសិទ្ធភាពជំនួយ» ហើយបានលើកបង្ហាញឯកសារក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី៤ ខែឧសភា ឆ្នាំ២០០០ នៅទីក្រុងប៉ារីស ។ ដៃគូអភិវឌ្ឍន៍ដែលមានវត្តមានក្នុងកិច្ចប្រជុំនោះ បានសំដែងការគាំទ្រយ៉ាងពេញទំហឹងលើគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល ។ ទស្សនវិស័យនេះបានបង្ហាញអំពីគំនិតជាមូលដ្ឋានសំខាន់ៗមួយចំនួនដែលទាក់ទងនឹងចរិតលក្ខណៈ រចនាសម្ព័ន្ធ និងជំរើសនានាក្នុងការកសាងភាពជាដៃគូជាមួយនឹងបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ សំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ។ ចាប់ពីពេលនោះមក រាជរដ្ឋាភិបាលបានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីសម្រេចឱ្យបាននូវទស្សនទានដែលបានកំណត់រួចមកនេះ ។

១៦- គោលការណ៍សំខាន់នៃកិច្ចសហប្រតិបត្តិការ គឺការកសាងភាពជាដៃគូដោយផ្អែកលើទស្សនទាន និងគោលដៅរួម មានការជឿទុកចិត្តគ្នាទៅវិញទៅមក មានការទទួលខុសត្រូវរួមគ្នា និងមានតម្លាភាពទ្វេទិស ។

គំនិតផ្តួចផ្តើមដែលរាជរដ្ឋាភិបាលបានលើកឡើង សម្រាប់កែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅ នៃក្រុមការងារបច្ចេកទេសចម្រុះក្នុងយន្តការកិច្ចប្រជុំពិគ្រោះយោបល់ កាលពីចុងឆ្នាំ ២០០៣ គឺជាជំហានដ៏សំខាន់នៃការកសាងភាពជាដៃគូសំរាប់កិច្ចអភិវឌ្ឍន៍ ។ ការកែសម្រួលក្រុមការងារទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ទាំងអស់ និងត្រូវបានអនុម័តដោយសម្តេចនាយករដ្ឋមន្ត្រី នៅក្នុងកិច្ចប្រជុំត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ ។ បច្ចុប្បន្ន យើងមានក្រុមការងារបច្ចេកទេសចម្រុះរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ចំនួន១៨ក្រុម ដែលកំពុងដំណើរការនៅតាមវិស័យសំខាន់ៗ ។ ដើម្បីពង្រឹងភាពជាម្ចាស់ ក្រុមការងារទាំងនេះត្រូវបានដឹកនាំដោយមន្ត្រីជាន់ខ្ពស់នៃស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល ។ រីឯដៃគូអភិវឌ្ឍន៍ក៏មានតំណាងរបស់ខ្លួន សម្រាប់សម្របសម្រួលការងារផងដែរ ។ ជាមួយគ្នានេះ «គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍» ត្រូវបានបង្កើតឡើងសម្រាប់សម្របសម្រួលការបំពេញភារកិច្ចរបស់ក្រុមការងារ ផ្តល់ការណែនាំក៏រិតគោលនយោបាយ និងកំណត់អាទិភាព ព្រមទាំងដោះស្រាយបញ្ហានានា ដែលក្រុមការងារចម្រុះបានជួបប្រទះក្នុងការងារ ។ សម្តេច នាយករដ្ឋមន្ត្រី បានចាត់តាំងឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានទីមួយនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អោយធ្វើជាប្រធាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងឯកឧត្តមអគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ជាអគ្គលេខាធិការនៃគណៈកម្មាធិការសម្របសម្រួលនេះ ។ សមាជិកនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ រួមមាន រដ្ឋមន្ត្រី ប្រធានស្ថាប័ន ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងតំណាងអ្នកផ្តល់ជំនួយទ្វេភាគី និងតំណាងស្ថាប័នផ្តល់ជំនួយពហុភាគី ។ គណៈកម្មាធិការសម្របសម្រួល ត្រូវជួបប្រជុំគ្នាទៀងទាត់ រៀងរាល់ត្រីមាសម្តង ដោយមានលេខាធិការដ្ឋានជាជំនួយការ ។

១៧- ការកែសម្រួលរចនាសម្ព័ន្ធក្រុមការងារចម្រុះ និងការបង្កើតគណៈកម្មាធិការសម្របសម្រួលរវាងរាជ-រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គឺជាបំលាស់ប្តូរខាងផ្នែកស្ថាប័នជាវិជ្ជមានមួយ សម្រាប់ការងារផែនការការងារគ្រប់គ្រង និងការងារតាមដានការអនុវត្តសកម្មភាពសហប្រតិបត្តិការរៀងរាល់បីខែម្តង ។ ការធានាអោយយន្តការនេះ បានដំណើរការប្រកបដោយប្រសិទ្ធភាព គឺជាការងារអាទិភាពរបស់រាជរដ្ឋាភិបាល ។ ក្នុងស្មារតីនេះ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ដែលជា «ចំណុចប្រមូលផ្តុំ» របស់រាជ-រដ្ឋាភិបាល ក្នុងការសម្របសម្រួលជំនួយ ត្រូវមានភារកិច្ចដូចខាងក្រោម ÷

ក- ទំនាក់ទំនងជាមួយក្រុមការងារ ដើម្បីតាមដានអំពីវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាព និងរៀបចំរបាយការណ៍ពីវឌ្ឍនភាពរបស់ក្រុមការងារ សម្រាប់បង្ហាញជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

ខ- បំពេញតួនាទីជា លេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។

គ- ផ្តល់ការគាំទ្រដល់ប្រធានក្រុមការងារបច្ចេកទេសចំរុះ ដើម្បីធានាឱ្យការផ្តល់ជំនួយរបស់ដៃគូអភិវឌ្ឍន៍អាចឆ្លើយតបនឹងអាទិភាពរបស់រាជរដ្ឋាភិបាល និងការធ្វើសុខដុមនីយកម្មក្នុងការអនុវត្តន៍របស់ដៃគូ

អភិវឌ្ឍន៍ ព្រមទាំងការពង្រឹងខាងស្ថាប័ន ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយនៅតាមវិស័យដែលក្រុមការងារកំពុងបំពេញភារកិច្ច ។

១៨- រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពដឹកនាំ និងភាពជាម្ចាស់ ក្នុងការកៀរគរធនធាន និងសម្របសម្រួលជំនួយដោយឈរលើគោលការណ៍នៃការទទួលខុសត្រូវរួមគ្នារវាងភាគីពាក់ព័ន្ធ ។ ចាប់តាំងពីឆ្នាំ១៩៩៦មក រាជរដ្ឋាភិបាលបានចាត់ទុក «កិច្ចប្រជុំពិគ្រោះយោបល់» ជាវេទិកាសម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ត្រួតពិនិត្យរួមគ្នា អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទំរង់នានា ដែលរាជរដ្ឋាភិបាលបានដាក់ចេញ និងជាយន្តការកៀរគរធនធានបរទេសសម្រាប់គាំទ្រសកម្មភាពទាំងនេះ ។ បើទោះជាកិច្ចប្រជុំពិគ្រោះយោបល់៥លើកដំបូងបានប្រារព្ធធ្វើនៅក្រៅប្រទេសក៏ដោយ ក៏រាជរដ្ឋាភិបាលបានទទួលការលើកទឹកចិត្ត និងកាន់តែមានទំនុកចិត្តបន្ថែមទៀត ចំពោះជោគជ័យនៃកិច្ចប្រជុំពិគ្រោះយោបល់២លើកចុងក្រោយ ដែលបានប្រព្រឹត្តនៅរាជធានីភ្នំពេញ ។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពជាម្ចាស់ក្នុងការកៀរគរធនធានសម្រាប់កិច្ចអភិវឌ្ឍន៍ប្រទេសបន្ថែមទៀត ដោយស្វែងរក និងប្រើប្រាស់ជំរើសទាំងអស់ដែលអាចមាន ដើម្បីអនុវត្តការងាររបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព ។

១៩- រីឯនៅលើឆាកអន្តរជាតិវិញ ចាប់តាំងពីឆ្នាំ១៩៩៩មក រាជរដ្ឋាភិបាលបានចូលរួមយ៉ាងសកម្មនៅក្នុងការងារសុខដុមនីយកម្ម ជាមួយគណៈកម្មាធិការជំនួយអភិវឌ្ឍន៍នៃអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលចាត់ទុកថា ឯកសារដែលបានរៀបចំឡើងដោយក្រុមការងារនៃគណៈកម្មាធិការជំនួយអភិវឌ្ឍន៍ ជាការចូលរួមចំណែកយ៉ាងសំខាន់របស់សហគមន៍អន្តរជាតិ ក្នុងកិច្ចប្រឹងប្រែងបង្កើនប្រសិទ្ធភាពនៃជំនួយ ។ ឯកសារដែលបានរៀបចំបញ្ចប់ក្នុងដំណាច់ឆ្នាំ ២០០២ ត្រូវបានបង្ហាញជូនវេទិកាកំរិតខ្ពស់លើកទីមួយ កាលពីខែកុម្ភៈ ឆ្នាំ២០០៣ នៅទីក្រុងរ៉ូម ។ រាជរដ្ឋាភិបាលក៏បានផ្តល់ការគាំទ្រដល់ការអនុវត្តន៍ការប្តេជ្ញាចិត្តនៃ «សេចក្តីប្រកាសទីក្រុងរ៉ូម» នៅក្នុងវេទិកាកម្រិតខ្ពស់នោះ ។ «សេចក្តីប្រកាសទីក្រុងរ៉ូម» បានបញ្ជាក់អំពីការប្តេជ្ញាជាក់លាក់ចំនួន៩ចំណុច ដោយផ្តល់សារៈសំខាន់លើចំណុចដូចខាងក្រោម ÷

ក- ជំនួយអភិវឌ្ឍន៍ផ្លូវការត្រូវឈរលើគោលការណ៍ភាពជាដៃគូពិតប្រាកដ និងការទទួលខុសត្រូវរួមគ្នារវាងដៃគូអភិវឌ្ឍន៍ និងប្រទេសជាដៃគូទទួលជំនួយ សំដៅសម្រេចឱ្យបានលទ្ធផលល្អប្រសើរ ។

ខ- ប្រទេសជាដៃគូទទួលជំនួយត្រូវធ្វើជាម្ចាស់និងដឹកនាំការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយប្រែក្លាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងនេះ ទៅជាកម្មវិធីប្រតិបត្តិការអាទិភាព ដោយភ្ជាប់ជាមួយលទ្ធផលជាក់លាក់ ។

គ- ប្រទេសជាដៃគូទទួលជំនួយនឹងដឹកនាំរាល់កិច្ចការគ្រប់គ្រង និងសម្របសម្រួលជំនួយ នៅគ្រប់កម្រិត ។

ឃ- ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវផ្តល់ជំនួយ ឱ្យស្របនឹងយុទ្ធសាស្ត្រនិងអាទិភាពអភិវឌ្ឍន៍របស់ប្រទេសជាដៃគូទទួលជំនួយ ។

ង- ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវធ្វើសុខដុមនីយកម្មនៃនីតិវិធីនិងការអនុវត្តរបស់ខ្លួន ជាមួយនឹងនីតិវិធីនិងការអនុវត្តរបស់ប្រទេសជាដៃគូ ។

ដើម្បីអនុវត្តការប្តេជ្ញានៃសេចក្តីប្រកាសទីក្រុងរ៉ូម រាជរដ្ឋាភិបាលបានរៀបចំផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ហើយត្រូវបានគណៈរដ្ឋមន្ត្រីអនុម័ត ក្នុងខែវិច្ឆិកា ឆ្នាំ២០០៤ កន្លងមក ។ ទន្ទឹមនេះដែរ ក៏បានចុះហត្ថលេខាលើ «សេចក្តីប្រកាសភាពជាដៃគូ»ជាមួយដៃគូអភិវឌ្ឍន៍ចំនួន១២ កាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៤ សំរាប់អនុវត្តផែនការសកម្មភាពនេះ ។ សមិទ្ធផលទាំងនេះ គឺជាជំហានវឌ្ឍនភាពនៃកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាពជំនួយ ។

២០- រាជរដ្ឋាភិបាលនៅតែបន្តផ្តល់អាទិភាពខ្ពស់ ដល់កិច្ចប្រឹងប្រែងបង្កើនប្រសិទ្ធភាពជំនួយ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ សំដៅឈានទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ។ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តំណាងអោយរាជរដ្ឋាភិបាល បានចូលរួមក្នុងវេទិកាកម្រិតខ្ពស់លើកទី២ ដែលបានប្រារព្ធនៅទីក្រុងប៉ារីស កាលពីខែមិនា ឆ្នាំ២០០៥ ដើម្បីពិនិត្យមើលពីវឌ្ឍនភាពដែលសម្រេចបានក្នុងការអនុវត្តការប្តេជ្ញានៃ «សេចក្តីប្រកាសទីក្រុងរ៉ូម» និងបណ្តាគោលការណ៍នានាដែលបានដាក់ចេញនៅក្នុងកិច្ចប្រជុំតុមូល Marrakech ស្តីពីការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល កាលពីខែកុម្ភៈ ឆ្នាំ២០០៤ ។ វេទិកាកម្រិតខ្ពស់លើកទី២នេះមានការចូលរួមពីថ្នាក់ដឹកនាំកំពូលនៃស្ថាប័នផ្តល់ជំនួយទ្វេភាគី និងពហុភាគី ព្រមទាំងរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍នៃប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ ។ នៅក្នុងវេទិកានេះ ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាអនុប្រធានទីមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តំណាងឱ្យរាជរដ្ឋាភិបាល បានធ្វើបទឧទ្ទេសនាមជូនវេទិកាកម្រិតខ្ពស់នេះ អំពីវឌ្ឍនភាពដែលកម្ពុជាសម្រេចបាន ក្នុងកិច្ចប្រឹងប្រែងលើកកំពស់ប្រសិទ្ធភាពជំនួយបរទេស ។ វេទិកាកម្រិតខ្ពស់បានចេញសេចក្តីប្រកាសមួយ ឈ្មោះថា «សេចក្តីប្រកាសទីក្រុងប៉ារីស» ។

២១- រាជរដ្ឋាភិបាលនឹងបន្តចូលរួមយ៉ាងសកម្មជាមួយបណ្តាស្ថាប័នផ្តល់ជំនួយអន្តរជាតិ ក្នុងការបង្កើនប្រសិទ្ធភាពជំនួយ ដើម្បីកាត់បន្ថយភាពក្រីក្រ សំដៅឈានទៅសម្រេចឱ្យបាននូវគោលដៅ សហសវត្សរ៍កម្ពុជា ។ ជាមួយគ្នានេះដែរ ក៏ចាត់វិធានការណ៍ចាំបាច់នានា ដើម្បីបន្តគាំទ្រ និងផ្តល់លទ្ធភាព ឱ្យគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងនិងស្ថាប័ន ពាក់ព័ន្ធ ដឹកនាំការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍ «សេចក្តីប្រកាសទីក្រុងរ៉ូម» និង «សេចក្តីប្រកាសទីក្រុងប៉ារីស» ។ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពដល់ការពង្រឹងសមត្ថភាពរបស់ក្រសួង និងស្ថាប័ន ដើម្បីបំពេញមុខងារទាំងនេះ ប្រកបដោយប្រសិទ្ធភាព ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលសូមស្វាគមន៍ចំពោះការគាំទ្រទាំងឡាយរបស់ដៃគូ អភិវឌ្ឍន៍សំរាប់ពង្រឹងសមត្ថភាពរបស់ក្រសួងនិងស្ថាប័នពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលក៏វាយតំលៃខ្ពស់ចំពោះកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ដែលបានជួយគាំទ្រគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៥ ក្នុងការរៀបចំគោលនយោបាយ សំរាប់គ្រប់គ្រងនិងសម្របសម្រួលជំនួយអភិវឌ្ឍន៍ផ្លូវការ ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយ ។ បន្ទាប់ពីការបញ្ចប់កម្មវិធីគាំទ្រ

ដែលមាននាពេលបច្ចុប្បន្ននេះ នាដំណាច់ឆ្នាំ២០០៥ កម្មវិធីគាំទ្រស្តីពី «ការសម្របសម្រួលជំនួយ និងភាពជាដៃគូ» សម្រាប់ដំណាក់កាលបន្ទាប់ នឹងត្រូវរៀបចំឡើងតាមអភិក្រម «ការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍ជាច្រើន» ។

## IV - គោលដៅនិងគោលការណ៍មូលដ្ឋាននៃយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

២២- គោលដៅចម្បងនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ គឺបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយបរទេសសម្រាប់អភិវឌ្ឍប្រទេស តាមរយៈការពង្រឹងប្រព័ន្ធ និងទម្រង់ការព្រមទាំងយន្តការសម្របសម្រួល និងកៀរគរជំនួយ ដោយឈរលើគោលការណ៍ «រាជរដ្ឋាភិបាលធ្វើជាម្ចាស់ និងដឹកនាំកិច្ចអភិវឌ្ឍ និងមានការទទួលខុសត្រូវរួមរវាងភាគីពាក់ព័ន្ធ» ដើម្បីអនុវត្តឱ្យបានសម្រេច នូវទិសដៅនៃ «យុទ្ធសាស្ត្រចតុកោណ» និងបណ្តាគោលដៅអាទិភាពនានានៃ «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ» ក្នុងការកាត់បន្ថយភាពក្រីក្រ ដើម្បីឈានទៅសម្រេចឱ្យបាននូវ «គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា» ។

២៣- ដើម្បីសំរេចគោលដៅខាងលើ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ជាមូលដ្ឋានដូចខាងក្រោម ÷

ក- គ្រប់គម្រោង និងកម្មវិធីអភិវឌ្ឍន៍របស់ដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល ត្រូវតែមានសង្គតិភាពជាមួយនឹងបណ្តាអាទិភាពនៃកិច្ចអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ។

ខ- ដៃគូអភិវឌ្ឍន៍ទ្វេភាគីនិងពហុភាគីទាំងអស់ និងអង្គការក្រៅរដ្ឋាភិបាល ត្រូវគោរពយ៉ាងពេញលេញនូវភាពជាម្ចាស់របស់រាជរដ្ឋាភិបាលលើគ្រប់គម្រោងនិងកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍ ។

គ- ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវផ្ទេរឱ្យបានច្រើនជាអតិបរមា ពីការផ្តល់ជំនួយតាមទម្រង់ការជាគម្រោងទោល ទៅជាការផ្តល់ជំនួយតាមវិស័យ ឬតាមកម្មវិធី និងឈានទៅរកការផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រថវិកា ។

ឃ- ចំពោះវិស័យណាដែលមិនទាន់មានគោលនយោបាយ និងយុទ្ធសាស្ត្រពេញលេញ ដៃគូអភិវឌ្ឍន៍ត្រូវផ្តល់ការគាំទ្រ ដើម្បីឱ្យក្រសួងនិងស្ថាប័នពាក់ព័ន្ធ មានលទ្ធភាពរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ តាមរយៈភាពជាដៃគូក្នុងក្រុមការងារបច្ចេកទេសចម្រុះ ។

ង- គម្រោង និងកម្មវិធីអភិវឌ្ឍន៍ទាំងអស់ ត្រូវមានសមាសភាគមួយផ្នែក (បើសិនជាចាំបាច់) សម្រាប់ការអភិវឌ្ឍសមត្ថភាពនៃក្រសួងនិងស្ថាប័ន ដែលមានភារកិច្ចអនុវត្តន៍គម្រោង និងកម្មវិធីទាំងនោះ។

ច- គម្រោង និងកម្មវិធីអភិវឌ្ឍន៍ទាំងអស់ត្រូវប្រើប្រាស់ឱ្យបានច្រើនជាអតិបរមា នូវយន្តការខាងស្ថាប័ន ប្រព័ន្ធផ្តល់សេវា និងធនធានមនុស្សរបស់កម្ពុជា ។

ឆ- សកម្មភាពនៃការអនុវត្តន៍គម្រោង និងកម្មវិធី ត្រូវតែមានភាពអាចទស្សទាយបានជាមុន និងត្រូវស្របតាមការិយបរិច្ឆេទនៃថវិកា ប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធត្រួតពិនិត្យ និងតាមដានរបស់កម្ពុជា ។

ជ- ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវធានាថា រាល់ការអនុវត្តន៍របស់ខ្លួនមិនបង្កើនបន្ទុកបន្ថែមទៀត ទាំងទិដ្ឋភាពរដ្ឋបាល និងទាំងការគ្រប់គ្រង មកលើក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាលឡើយ ហើយត្រូវធានាឱ្យបាន នូវសុខដុមនីយកម្មនិងការធ្វើអោយសាមញ្ញនូវការអនុវត្តរបស់ខ្លួន ។

ឈ- រាជរដ្ឋាភិបាលនឹងបន្តអនុវត្តន៍បណ្តាកម្មវិធីកំណែទម្រង់ សំដៅកែលំអយន្តការខាងស្ថាប័ន និងទម្រង់ការអនុវត្តនានា ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

ញ- រាជរដ្ឋាភិបាលនឹងពង្រឹងការដឹកនាំក្នុងគ្រប់យន្តការកៀរគរនិងសម្របសម្រួលជំនួយ ដើម្បីធានាតម្លាភាព និងគណនេយ្យភាព សម្រាប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ។

២៤- ការអនុវត្តកម្មវិធីនិងគម្រោងទាំងអស់នៃជំនួយអភិវឌ្ឍន៍ផ្លូវការ ត្រូវចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ ដើម្បីសម្រេចឱ្យបាន នូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ។ រាជរដ្ឋាភិបាលបានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុងទិសដៅសម្រេចឱ្យបាននូវគោលដៅជាសារវន្តទាំងនេះ ។ កម្មវិធី និងគម្រោងអភិវឌ្ឍន៍ទាំងអស់ ត្រូវគាំទ្របណ្តាអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយត្រូវចូលរួមគាំទ្រ និងជម្រុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងសមធម៌ តាមរយៈការលើកកំពស់ផលិតភាពនៃខឿនសេដ្ឋកិច្ចជាតិ ការកសាងសមត្ថភាពធនធានមនុស្ស និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ សំរាប់គាំទ្រដល់កិច្ចដំណើរការអភិវឌ្ឍន៍នេះ ។ ក្នុងបរិបថនៃកិច្ចអភិវឌ្ឍន៍របស់កម្ពុជានាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលបានផ្តល់អាទិភាពជាចម្បង ទៅលើបណ្តាគម្រោងនិងកម្មវិធីក្នុងក្របខ័ណ្ឌជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍ ។

២៥- ចំពោះកម្មវិធីនិងគម្រោងវិនិយោគទាំងឡាយ ដែលជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ហើយដែលមិនអាចស្វែងរកជំនួយឥតសំណងបាន រាជរដ្ឋាភិបាលអាចស្វែងរកប្រភពហិរញ្ញប្បទានជាកម្ចី សម្រាប់អនុវត្តកម្មវិធីនិងគម្រោងទាំងនេះ ។ ក្នុងករណីនេះ រាជរដ្ឋាភិបាលនឹងពិនិត្យឱ្យបានហ្មត់ចត់ជាមុន នូវផលប៉ះពាល់នៃកម្មវិធីនិងគម្រោងកម្ចីទាំងនេះ រួមទាំង ផលប៉ះពាល់លើស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ កម្ចីអាចប្រើប្រាស់សម្រាប់អនុវត្តកម្មវិធី និងគម្រោងដូចខាងក្រោម ÷

ក- គម្រោងនិងកម្មវិធីផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដែលអាចផ្តល់ផលប្រយោជន៍ខ្លាំងក្លាដល់សេដ្ឋកិច្ចជាតិ ហើយគម្រោងវិនិយោគនេះត្រូវមានអត្រាចំណូលផ្ទៃក្នុងខ្ពស់ ។

ខ- គម្រោងនិងកម្មវិធីទាំងឡាយ ដែលជំរុញឱ្យមានការអភិវឌ្ឍន៍អន្តរកម្មនៃពាណិជ្ជកម្មក្រៅប្រទេស ដែលអាចលើកកំពស់សមត្ថភាពរបស់រដ្ឋ ក្នុងការប្រមូលចំណូលជារូបិយប័ណ្ណអន្តរជាតិ ។

ចំពោះគម្រោងនិងកម្មវិធីអភិវឌ្ឍន៍ធំៗដែលនឹងត្រូវធ្វើហិរញ្ញប្បទានដោយកម្ចី ហើយដែលទាមទារឱ្យមានសមិទ្ធសិក្សា ឬការវិភាគផ្សេងៗទៀតមុនធ្វើវិនិយោគ ការសិក្សាទាំងនេះត្រូវតែប្រើប្រាស់ជំនួយឥតសំណង ។ រាជរដ្ឋាភិបាលនឹង ÷

ក- បញ្ឈប់ការប្រើប្រាស់កម្ចី សម្រាប់ការសិក្សាទាំងឡាយណា ដែលមិនពាក់ព័ន្ធផ្ទាល់នឹងកម្មវិធីនិងគម្រោងវិនិយោគ ។

ខ- កាត់បន្ថយឱ្យបានច្រើនបំផុតនូវការប្រើប្រាស់កម្ចី សម្រាប់ចំណាយលើសេវាទីប្រឹក្សាបរទេស ។

២៦- រីឯជំនួយបច្ចេកទេស ក៏ត្រូវចូលរួមក្នុងការអនុវត្តន៍ឱ្យបានសម្រេច នូវបណ្តាគោលដៅអភិវឌ្ឍន៍ប្រទេសផងដែរ ។ ការប្រើប្រាស់ជំនួយបច្ចេកទេសនិងអ្នកជំនាញការបរទេសក៏ត្រូវគិតគូរអោយបានត្រឹមត្រូវ ដោយត្រូវ សម្រិតសម្រាំង និងត្រូវកាត់បន្ថយជាបណ្តើរៗ ដោយត្រូវកសាងសមត្ថភាពក្នុងស្រុក តាមរយៈការផ្ទេរពុទ្ធិ និងបច្ចេកវិទ្យា ។ ក្នុងការរៀបចំផែនការប្រើប្រាស់ជំនួយបច្ចេកទេស ចំណុចដែលត្រូវយកចិត្តទុកដាក់គឺ ជំនួយបច្ចេកទេសពិតជាសម្រាប់ផ្តល់ការគាំទ្រ មិនមែនមកធ្វើជំនួសឡើយ ហើយត្រូវឆ្លើយតបនឹងតម្រូវការ ។ ជំនួយបច្ចេកទេសនឹងត្រូវបានប្រើប្រាស់ សម្រាប់អនុវត្តកម្មវិធី និងគម្រោងធំៗ សម្រាប់អនុវត្តកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល និងការងារដទៃទៀត ដែលពាក់ព័ន្ធនឹងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចជាតិ ព្រមទាំងសម្រាប់កសាងសមត្ថភាពនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន ដើម្បីរៀបចំ អនុវត្ត និងតាមដានវាយតម្លៃសកម្មភាពអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលមិនលើកទឹកចិត្តឱ្យប្រើប្រាស់កម្ចី សម្រាប់ជំនួយបច្ចេកទេសឡើយ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏មិនលើកទឹកចិត្តឱ្យដៃគូអភិវឌ្ឍន៍ជាច្រើន ធ្វើការសិក្សាលើប្រធានបទតែមួយឡើយ ហើយស្នើឱ្យដៃគូអភិវឌ្ឍន៍ពិភាក្សា និងឯកភាពជាមុនជាមួយរាជរដ្ឋាភិបាល មុននឹងផ្សព្វផ្សាយឯកសារនិងរបាយការណ៍នានារបស់ខ្លួន ។

## V - កម្មវិធីជាតិសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

២៧- រាជរដ្ឋាភិបាលទទួលស្គាល់ថា ការគ្រប់គ្រង និងការសម្របសម្រួលនូវរាល់សកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព គឺជាគន្លឹះដ៏សំខាន់ ដើម្បីប្រើប្រាស់ជំនួយឱ្យស្របទៅនឹងអាទិភាពអភិវឌ្ឍន៍របស់ប្រទេស ។ ទន្ទឹមនេះដែរ ក៏បង្កើនការធ្វើសុខដុមនីយកម្មនៃរាល់ការអនុវត្តន៍របស់ដៃគូអភិវឌ្ឍន៍ ដើម្បីកាត់បន្ថយបន្ទុកខាងផ្នែកសមត្ថភាពមកលើក្រសួងនិងស្ថាប័នរាជរដ្ឋាភិបាល និងដើម្បីប្រើប្រាស់អោយបាន ជាអតិបរមានិងមានប្រសិទ្ធភាពនូវជំនួយសម្រាប់កិច្ចអភិវឌ្ឍន៍ប្រទេស ។ ការគ្រប់គ្រងនិងសម្របសម្រួលជំនួយ មានវិសាលភាព និងទិដ្ឋភាពប្លែកៗពីគ្នា ។ ដើម្បីអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ រាជរដ្ឋាភិបាលនឹងរៀបចំកម្មវិធីជាតិ ដោយត្រូវផ្តោតលើទិដ្ឋភាពសំខាន់ៗ ដូចខាងក្រោម ÷

ក- ពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័ន «ចំណុចប្រមូលផ្តុំ»របស់រាជរដ្ឋាភិបាល ក្នុងការកៀរគរនិងសម្របសម្រួលជំនួយ ។ ទន្ទឹមនេះ ក៏ត្រូវផ្តល់សេវាប្រឹក្សាករិតគោលនយោបាយ សម្រាប់ថ្នាក់ដឹកនាំនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ទាំងក្នុងប្រទេសនិងក្រៅប្រទេស ។

ខ- ពង្រឹងសមត្ថភាពរបស់ក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល សម្រាប់គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវជំនួយបរទេស ដែលក្រសួងនិងស្ថាប័ននិមួយៗទទួលខុសត្រូវ ដោយត្រូវសម្របសម្រួលការងារ ជាមួយនឹងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ។

២៨- ការបន្តពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា គឺជាកិច្ចការចាំបាច់ ដែលត្រូវអនុវត្តបន្ត ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាព នូវបណ្តាភារកិច្ចដែលកាន់តែមានទំហំច្រើនឡើងៗ ។ ភារកិច្ចទាំងនេះរួមមាន ÷

ក- ដឹកនាំកិច្ចពិភាក្សាកំរិតគោលនយោបាយ ជាមួយដៃគូអភិវឌ្ឍន៍ទ្វេភាគីនិងពហុភាគី លើយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ដៃគូអភិវឌ្ឍន៍ និងបំពេញតួនាទីជា «ចំណុចប្រមូលផ្តុំ» របស់រាជរដ្ឋាភិបាល លើបញ្ហាជំនួយអភិវឌ្ឍន៍ជាមួយដៃគូអភិវឌ្ឍន៍ ។

ខ- រៀបចំឯកសារសំខាន់ៗរបស់រាជរដ្ឋាភិបាលសម្រាប់កៀរគរជំនួយ ។

គ- កសាងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើនប្រសិទ្ធភាពជំនួយ ។

ឃ- គ្រប់គ្រងពតិមាន និងទិន្នន័យស្តីពីលំហូរជំនួយ និងរៀបចំរបាយការណ៍សហប្រតិបត្តិការអភិវឌ្ឍន៍ ព្រមទាំងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ។

ង- ចូលរួមក្នុងវេទិកានៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ និងវេទិកាអន្តរជាតិដទៃទៀតស្តីពីប្រសិទ្ធភាពជំនួយ ព្រមទាំងតាមដានវឌ្ឍនភាពនៃការអនុវត្តន៍សេចក្តីប្រកាសទីក្រុងរ៉ូម និងសេចក្តីប្រកាសទីក្រុងប៉ារីស ។

ច- តាមដានវឌ្ឍនភាពនៃការអនុវត្តន៍ការប្តេជ្ញាចិត្តនានារបស់រាជរដ្ឋាភិបាលនៅ ក្នុងវេទិកាអន្តរជាតិនានា ពិសេសផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម ។

ឆ- ពង្រឹងយន្តការនៃក្រុមការងារបច្ចេកទេសចម្រុះ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជ-រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ តាមរយៈ ÷

- ពង្រឹងទំនាក់ទំនងជាមួយក្រុមការងារបច្ចេកទេសចម្រុះ និងតាមដានវឌ្ឍនភាពដែលក្រុមការងារសម្រេចបាន ក្នុងការអនុវត្តន៍ផែនការសកម្មភាពតាមវិស័យរបស់ខ្លួន ដើម្បីរាយការណ៍ ជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។
- បំពេញតួនាទីជាលេខាធិការដ្ឋានអោយបានពេញលេញ ដើម្បីគាំទ្រដល់ការងាររបស់គណៈ-កម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។
- ផ្តល់ការគាំទ្រដល់ប្រធានក្រុមការងារ ដើម្បីធានាសង្គតិភាពនៃសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ ជាមួយនឹងអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងពង្រឹងសមត្ថភាពខាងស្ថាប័ន ដើម្បីបង្កើនប្រសិទ្ធភាព និងសុខដុមនីយកម្មនៃជំនួយបរទេសនៅតាមវិស័យនៃក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ ។
- ដើរតួនាទីជាស្ថាប័នស្នូលរបស់រាជរដ្ឋាភិបាលក្នុងដំណើរការកៀរគរធនធានក្រៅប្រទេស ។

២៩- ការពង្រឹងសមត្ថភាពប្រកបដោយចីរភាពរបស់ក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ក៏ជាកិច្ចការដែលត្រូវធ្វើជាចាំបាច់ផងដែរ ដើម្បីពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំរបស់ក្រសួងនិងស្ថាប័ន ក្នុងការគ្រប់គ្រង និងសម្របសម្រួលជំនួយបរទេស ។ ភារកិច្ចទាំងនេះរួមមាន ÷

ក- តម្រែតម្រង់ការផ្តល់ជំនួយឱ្យស្របនឹងបណ្តាអាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ហើយក៏ត្រូវធានាផងដែរ អោយមានតុល្យភាពរវាងឧបិរចនាសម្ព័ន្ធនិងហេដ្ឋារចនាសម្ព័ន្ធ ។

ខ- ពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំរបស់ក្រុមការងារបច្ចេកទេសចម្រុះ និងរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ និងសមាជិកនៃក្រុមការងារ ដើម្បីចូលរួមដោះស្រាយភ្លាមៗនូវបណ្តាបញ្ហាទាំងឡាយរបស់ក្រុមការងារ ដោយមិនបាច់រង់ចាំកិច្ចប្រជុំកំរិតខ្ពស់ជាងនេះសម្រាប់ ដោះស្រាយបញ្ហាទាំងនេះឡើយ ។

គ- កាត់បន្ថយចំនួនគម្រោងទោលជាបណ្តើរៗ ដោយឈានទៅអនុវត្តអភិក្រមគ្រប់គ្រងទូទាំងវិស័យ ឬអភិក្រមគ្រប់គ្រងតាមកម្មវិធី ។

ឃ- ស្វែងរកមធ្យោបាយ ដើម្បីកាត់បន្ថយចំនួនអង្គភាពអនុវត្តន៍គំរោង អ្នកជំនាញការបរទេស និងជំនួយបច្ចេកទេស ដោយត្រូវពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ។

៣០- រាជរដ្ឋាភិបាលនៅតែបន្តការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំក្នុងការរៀបចំផែនការ ការគ្រប់គ្រង និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ ដើម្បីបង្កើនប្រសិទ្ធភាពជំនួយ សម្រាប់ផ្តល់អត្ថប្រយោជន៍ឱ្យបានច្រើនបំផុតដល់ប្រជាជនកម្ពុជា ។ ការងារដ៏សំខាន់មួយក្នុងចំណោមបណ្តាអាទិភាពរបស់រាជរដ្ឋាភិបាលសម្រាប់បង្កើនប្រសិទ្ធភាពជំនួយ គឺជំរុញនិងលើកទឹកចិត្តអោយមានការវិនិយោគកាន់តែខ្លាំងក្លាថែមទៀត ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងកសាងសមត្ថភាពធនធានមនុស្ស សំដៅកាត់បន្ថយភាពក្រីក្រ និងសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីតម្រែតម្រង់ការប្រើប្រាស់ធនធានក្រៅប្រទេស ឱ្យបានចំទិសដៅជាងមុន ។ រាជរដ្ឋាភិបាលសូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ ចូលរួមអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ និងផ្តល់ការគាំទ្ររបស់ខ្លួនតាមរយៈកម្មវិធីដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាច្រើន ។

--------

# ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ១៤៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- អនុលោមតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

### ជំពូកទី ១
### ការរៀបចំនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា ១ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាហៅកាត់ថា « ក.អ.ក » មានសមាសភាពដូចតទៅ÷

| | | |
|---|---|---|
| ១- សម្តេច ហ៊ុន សែន | នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល | សហប្រធាន |
| ២- សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ | ទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល | សហប្រធាន |

៣- ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១

៤- ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អនុប្រធាន

៥- ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
មានឋានៈស្មើរដ្ឋមន្ត្រី អនុប្រធាន

៦- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង សមាជិក

៧- រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ឬតំណាង សមាជិក

៨- សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង សមាជិក

៩- សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតំណាង សមាជិក

១០- រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ឬតំណាង សមាជិក

១១- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬតំណាង សមាជិក

១២- រដ្ឋមន្ត្រីក្រសួងពត៌មាន ឬតំណាង សមាជិក

១៣- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ឬតំណាង សមាជិក

១៤- រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាង សមាជិក

១៥- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ឬតំណាង សមាជិក

១៦- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬតំណាង សមាជិក

១៧- រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ឬតំណាង សមាជិក

១៨- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ឬតំណាង សមាជិក

១៩- រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតំណាង សមាជិក

២០- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឬតំណាង សមាជិក

២១- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬតំណាង សមាជិក

២២- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬតំណាង សមាជិក

២៣- រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង សមាជិក

២៤- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬតំណាង សមាជិក

២៥- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង សមាជិក

២៦- រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ឬតំណាង សមាជិក

២៧- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង សមាជិក

២៨- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬតំណាង សមាជិក

២៩- រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឬតំណាង សមាជិក

៣០- រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា ឬតំណាង សមាជិក

៣១- អគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា ឬតំណាង សមាជិក

៣២- រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ឬតំណាង សមាជិក

៣៣- រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬតំណាង សមាជិក

៣៤- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ឬតំណាង សមាជិក

៣៥- អគ្គស្នងការនគរបាលជាតិ ឬតំណាង សមាជិក

៣៦- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ឬតំណាង សមាជិក

៣៧- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា សមាជិក

៣៨- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៏កម្ពុជា សមាជិក

៣៩- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

៤០- អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា សមាជិក

៤១- អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា សមាជិក

៤២- អភិបាលខេត្ត-ក្រុង ឬ តំណាង សមាជិក

៤៣- ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ឬ តំណាង សមាជិក

**មាត្រា ២ :** ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

១- គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៏កម្ពុជា ហៅកាត់ « គ.ជ.នា» ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាមួយរូប ។

២- គណៈកម្មាធិការវិនិយោគកម្ពុជា ហៅកាត់ « គ.វ.ក» ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប ។

៣- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ហៅកាត់ « គ. ស.៣» ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប ។

៤- អគ្គលេខាធិការដ្ឋាននៃ « ក.អ.ក » ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ អគ្គលេខាធិការ « ក.អ.ក » ។

**មាត្រា ៣ :** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៏ កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា និង អគ្គលេខាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានអគ្គលេខាធិការរងមួយរូបៗរៀងៗខ្លួនសម្រាប់ជាជំនួយការក្នុងការងារ ។ អគ្គលេខាធិការរងនីមួយៗត្រូវបំពេញកិច្ចការតាមភារកិច្ច ដែលអគ្គលេខាធិការប្រគល់ឱ្យ ក្រោយពីបានពិភាក្សាឯកភាពជាមួយគណៈកម្មាធិការប្រតិបត្តិ នៃ «ក.អ.ក »។ អគ្គលេខាធិការមួយរូបៗ ត្រូវបំពេញការងារដោយផ្លាស់ប្តូរយោបល់ជាប្រចាំជាមួយអគ្គលេខាធិការរងរបស់ខ្លួន ។

**មាត្រា ៤ :** គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

១- ផ្នែកទំនាក់ទំនងសាធារណៈ កៀរគរ និង សម្របសម្រួលជំនួយ

២- ផ្នែកឯកសារ និង គ្រប់គ្រងពត៌មាន

៣- ផ្នែកគ្រប់គ្រងជំនួយទ្វេភាគី ជាមួយបណ្តាប្រទេសនៅទ្វីបអាស៊ី និងអូសេអានី

៤- ផ្នែកគ្រប់គ្រងជំនួយទ្វេភាគី ជាមួយបណ្តាប្រទេសនៅទ្វីបអឺរ៉ុប និងសហគមន៍អឺរ៉ុប និងទ្វីបអាមេរិក

៥- ផ្នែកគ្រប់គ្រងជំនួយពហុភាគី (ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និង មូលនិធិរូបិយវត្ថុអន្តរជាតិ ។ល។)

៦- ផ្នែកគ្រប់គ្រងជំនួយរបស់កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ និង បណ្តាអង្គការរបស់សហប្រជាជាតិ

៧- ផ្នែកសម្របសម្រួល និង ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល

៨- ផ្នែកវិភាគគម្រោង

៩- ផ្នែករដ្ឋបាល ។

**មាត្រា ៥ :** គណៈកម្មាធិការវិនិយោគកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ÷

១- ផ្នែកទំនាក់ទំនងសាធារណៈ និង ការជម្រុញគម្រោងវិនិយោគឯកជន

២- ផ្នែកវិភាគគម្រោង និង ការលើកទឹកចិត្ត

៣- ផ្នែកវាយតំលៃខាងបរិស្ថាន

៤- ផ្នែកសម្របសម្រួលកិច្ចការអន្តរក្រសួង

៥- ផ្នែកវិភាគយុទ្ធសាស្ត្រនៃការវិនិយោគឯកជន

៦- ផ្នែកនីតិកម្ម និង ច្បាប់វិនិយោគ

៧- ផ្នែកត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ

៨- ផ្នែករដ្ឋបាល

**មាត្រា ៦ :** គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ÷

១- ផ្នែកគោលនយោបាយ និងផែនការ

២- ផ្នែកប្រតិបត្តិការ និងគ្រប់គ្រង

៣- ផ្នែកចុះបញ្ជី និងសិក្សាគម្រោង

៤- ផ្នែករដ្ឋបាល

**មាត្រា ៧ :** អគ្គលេខាធិការដ្ឋានរួមមាន « ផ្នែកគាំទ្រ » ចំនួន ៤ ÷

១- ផ្នែកនីតិកម្ម និង ដោះស្រាយវិវាទ

២- ផ្នែកហិរញ្ញវត្ថុ និង រដ្ឋបាល

៣- ផ្នែកគ្រប់គ្រងមន្ត្រី និង បុគ្គលិក

៤- ផ្នែកផែនការនីយកម្មយុទ្ធសាស្ត្រ ។

**មាត្រា ៨ :** ផ្នែក និងផ្នែកគាំទ្រនីមួយៗ មានថ្នាក់ស្មើនឹងនាយកដ្ឋាន ហើយដឹកនាំដោយប្រធានមួយរូប ព្រមទាំងមានអនុប្រធានមួយរូប ឬ ច្រើនរូបជាជំនួយការ ។

**មាត្រា ៩ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការប្រតិបត្តិសម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ។

គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមាសភាពដូចតទៅ ÷

១- សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

២- អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៤- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា

៥- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា

៦- អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ។

## **ជំពូកទី ២**
## **សមត្ថកិច្ច និង ភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**មាត្រា ១០ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ហើយមានភារកិច្ចដូចតទៅ ÷

១- ជាសេនាធិការ និង ជា « ច្រកចេញចូលតែមួយ » របស់រាជរដ្ឋាភិបាល ក្នុងការទទួលបន្ទុកកិច្ចការ នីតិសម្បទា និងអភិវឌ្ឍន៍និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន និង ការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ។

២- ដឹកនាំការងាររៀបចំទស្សនទាន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ សម្រាប់ប្រទេសកម្ពុជាដោយសហការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ ។

៣- ទាក់ទងជាមួយប្រទេស អង្គការអន្តរជាតិពហុភាគី/ទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ក្នុងគោលបំណងធ្វើអោយគេយល់ជ្រួតជ្រាបអំពីទស្សនទានយុទ្ធសាស្ត្រសេដ្ឋកិច្ច និងបណ្តាអាទិភាពនៃកម្មវិធី

ជាតិសម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍ប្រទេស ដើម្បីសម្របសម្រួលការទទួលនិងការប្រើប្រាស់ជំនួយអន្តរជាតិអោយមានប្រសិទ្ធភាព ស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ។

៤- សម្របសម្រួលការងាររវាងក្រសួង និង ស្ថាប័ននានា ដែលមានការពាក់ព័ន្ធ ជាមួយនឹងប្រទេស និង អង្គការអន្តរជាតិអ្នកផ្តល់ជំនួយ ព្រមទាំងជាមួយអ្នកវិនិយោគ ។

៥- តម្រង់ទិសក្នុងការបែងចែក និង ក្នុងការប្រើប្រាស់ធនធានសាធារណៈ និង ធនធានឯកជន ក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា ។

៦- បង្កលក្ខណៈងាយស្រួល និង សម្រួលកិច្ចការដល់អ្នកផ្តល់ជំនួយ និង ដល់អ្នកវិនិយោគ ។

៧- ពិនិត្យ និងសម្រេចរាល់កិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន និងការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ។

**មាត្រា ១១ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសុំយោបល់សម្រេចពីគណៈរដ្ឋមន្ត្រី លើគម្រោងវិនិយោគទាំងឡាយដែលមានលក្ខណៈសម្បត្តិណាមួយដូចតទៅ÷

១- ទំហំទុនវិនិយោគសរុបចាប់ពី ៥០ លានដុល្លារអាមេរិក ឡើងទៅ

២- មានវេទយិតភាពខាងនយោបាយ

៣- ការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ

៤- អាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន

៥- គម្រោងយុទ្ធសាស្ត្ររយៈពេលវែង

៦- គំរោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ

**មាត្រា ១២ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខគណៈរដ្ឋមន្ត្រី អំពីសកម្មភាពរបស់ខ្លួន ។

**មាត្រា ១៣ :** ក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ ÷

១- ធ្វើជាចំណុចប្រមូលផ្តុំ និងជា «ច្រកចេញចូលតែមួយ» ក្នុងការទាក់ទងរវាងរាជរដ្ឋាភិបាលជាមួយ នឹងប្រទេស អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលជាអ្នកផ្តល់ជំនួយដល់កម្ពុជា និងធ្វើជាចំណុចប្រមូលផ្តុំ និងជា «ច្រកចេញចូលតែមួយ» ក្នុងការទាក់ទងរវាងស្ថាប័ននានា នៃរាជរដ្ឋាភិបាលដើម្បីសម្របសម្រួលការទទួលជំនួយ និង /ឬ ការបែងចែកជំនួយ ។

២- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីពង្រឹងភាពជាម្ចាស់និងភាពដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ ព្រមទាំងពង្រឹងភាពជាដៃគូជាមួយសហគមន៍អ្នកផ្តល់ជំនួយ ។

៣- កៀរគរ និងវិភាជន៍ជំនួយបរទេស សំរាប់អនុវត្តបណ្តាគោលដៅអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍តាមវិស័យ ។

៤- ដឹកនាំផ្ទាល់កិច្ចការសុខដុមនីយកម្មនៃការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើនប្រសិទ្ធភាពនៃជំនួយ បទេស។

៥- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដល់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលជាយន្តការសំរាប់ពិភាក្សាក៏រិតគោលនយោបាយ និងផ្តល់ការគាំទ្រនានាសំរាប់ពង្រឹងយន្តការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។

៦- រួមជាមួយក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំទស្សនាទានជាយុទ្ធសាស្ត្រសម្រាប់និតិសម្បទា និងអភិវឌ្ឍន៍ប្រទេសនិងដើម្បីលើកឡើងនូវលំដាប់អាទិភាពនៃតម្រូវការរបស់ប្រទេសជាតិ ក្នុងពេលបច្ចុប្បន្នជាបន្ទាន់និងសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីបង្កើតឡើងនូវកម្មវិធីការងាររំកិលតាមឆ្នាំ។ កម្មវិធីនេះ ត្រូវមានលក្ខណៈជាប្រព័ន្ធរលូនប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នា។

7- ចូលរួមរៀបចំផែនការសេដ្ឋកិច្ច សង្គមកិច្ច និងផែនការតាមផ្នែកសម្រាប់អភិវឌ្ឍន៍កម្ពុជា។

៨- គ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង និងស្ថាប័នទាំងឡាយដែលមានការពាក់ព័ន្ធ ។ការងារនេះពាក់ព័ន្ធសំខាន់ទៅនឹងការសម្របសម្រួល និងការតំរង់ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធាននៅក្នុងប្រទេស និងធនធានដែលបានមកពីក្រៅប្រទេសដើម្បីកិច្ចការស្តារ និងអភិវឌ្ឍន៍កម្ពុជា។

៩- តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាលជាមួយនឹងអ្នកផ្តល់ជំនួយទ្វេភាគី ពហុភាគី និង/ឬ អង្គការអន្តរជាតិនានា ដើម្បីទទួលជំនួយ និង /ឬ ការបែងចែកជំនួយ ។

១០-ដឹកនាំការងារក្នុងការរៀបចំឯកសារចាំបាច់នានាសម្រាប់កិច្ចប្រជុំអន្តរជាតិ សម្រាប់ការកសាងប្រទេសកម្ពុជាឡើងវិញដូចជា «ក្រុមពិគ្រោះយោបល់សម្រាប់កម្ពុជា » ជាដើម ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ។

១១-ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលំអ និងតម្រង់ទិសការងារនីតិសម្បទា និងអភិវឌ្ឍន៍។

**មាត្រា ១៤ :** ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ÷

១- «ក.អ.ក »ជាអ្នកសម្របសម្រួលក្នុងការលើកទស្សនទានជាយុទ្ធសាស្ត្រ និងគោលនយោបាយនៃកិច្ចការវិនិយោគសាធារណៈ ព្រមទាំងជាអ្នកសម្របសម្រួល ក្នុងការកំណត់ លំដាប់អាទិភាពនៃកម្មវិធី និងគម្រោងវិនិយោគសាធារណៈសម្រាប់រយៈពេលមធ្យម និងរយៈពេលមួយឆ្នាំ។

២- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាបង្អួចការទូតផ្លូវការ ។

៣- ក្រសួងផែនការ សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ជាអ្នករៀបចំផែនការ ៥ ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ ។

៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នករៀបចំការប៉ាន់ស្មានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ជាអ្នករៀបចំថវិកា សម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ និងជាអ្នកត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទាន ។

៥- ក្រសួងជំនាញ ជាអ្នករៀបចំកម្មវិធី និងគម្រោងការវិនិយោគសាធារណៈតាមផ្នែកដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ និងជាមួយ«ក.អ.ក» ព្រមទាំង ជាមួយអ្នកអនុវត្តកម្មវិធី និងគម្រោងការវិនិយោគសាធារណៈតាមផ្នែក ដែលមានការពាក់ព័ន្ធទៅនឹងជំនាញរបស់ខ្លួន ។

**មាត្រា ១៥** : ក្រសួង និងស្ថាប័ន ត្រូវធ្វើការងារនិងបំពេញកាតព្វកិច្ចរបស់ខ្លួន ខាងវិនិយោគសាធារណៈដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ «ច្រកចេញចូលតែមួយ» ។

**មាត្រា ១៦** : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័ន ត្រូវតាមដានការអនុវត្តន៏កម្មវិធី និង/ឬ គម្រោងស្របតាមសមត្ថកិច្ចរៀង១ខ្លួនដោយសម្របសម្រួលការងារជាមួយគ្នា តាមរយៈយន្តការ «ច្រកចេញចូលតែមួយ » ។

**មាត្រា ១៧** : ក្នុងកិច្ចការវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ច ដូចតទៅ÷

១- បំពេញតួនាទីជាយន្តការ «ច្រកចេញចូលតែមួយ» និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និង សម្រេចលើការវិនិយោគនានាដូចបានកំណត់នៅក្នុងមាត្រា ៣ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

២- ធ្វើការវិភាគ «ការប្រណាំងប្រជែងដណ្តើមឈ្នះ» លើទីផ្សារអន្តរជាតិសម្រាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការវិនិយោគឯកជនសម្រាប់ប្រទេសកម្ពុជា និងសម្រេចអោយបាននូវទស្សនៈនេះដោយធ្វើអោយប្រទេសកម្ពុជាក្លាយទៅជា «សាជីវកម្មកម្ពុជា» ។ សហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធដើម្បីរៀបចំយុទ្ធសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគម្រោងនានា សម្រាប់ការវិនិយោគឯកជន ។

៣- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគឯកជន ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅអោយអ្នកវិនិយោគ តាមនីតិវិធី ដែលមានចែងនៅក្នុងបទបញ្ញត្តិផ្ទៃក្នុង នៃ «ក.អ.ក » ។

៤- សម្របសម្រួលការគ្រប់គ្រងគម្រោង សម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ ។

៥- លើកគម្រោង និងផ្តល់យោបល់ជូនរដ្ឋាភិបាល ស្តីអំពីការរៀបចំ និងការកែលំអច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទិននឹងការវិនិយោគឯកជន ក្នុងគោលបំណងបង្កើតល័ក្ខខ័ណ្ឌ ដែល អនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគឯក ជន ។

៦- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានា ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជនសម្រាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និង ក្រៅប្រទេស ។

៧- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលំអ និងតម្រង់ទិសការងារវិនិយោគឯកជន ។

**មាត្រា ១៨** : ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគឯកជន ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាលត្រូវកំណត់ដូចតទៅ÷

១- «ក.អ.ក» បំពេញតួនាទីជា «ច្រកចេញចូលតែមួយ» របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា រាប់ទាំងសកម្មភាពរុករក-ស្រាវជ្រាវ-ការធ្វើអាជីវកម្មប្រេងកាត-ឧស្ម័ន និងធនធានធម្មជាតិផ្សេងៗ ទោះបីគំរោងខ្លះ មិនត្រូវបានទទួលការលើកទឹកចិត្តក៏ដោយ ។

២- ក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា ក្នុងក្របខ័ណ្ឌនៃយន្តការ «ច្រកចេញចូលតែមួយ» ។

**មាត្រា ១៩** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង ស្ថាប័ននានា ដែលមានការពាក់ព័ន្ធធ្វើការងារ និងបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការគ្រប់គ្រងការវិនិយោគឯកជន ដោយសម្របសម្រួលការងារជាមួយគ្នា តាមរយៈយន្តការ «ច្រកចេញចូលតែមួយ» ។

**មាត្រា ២០** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមជាមួយ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួង ឬ ស្ថាប័ន ដែលមានការពាក់ព័ន្ធ ជាអ្នកតាមដានការអនុវត្តគម្រោងវិនិយោគឯកជន ដែល«ក.អ.ក» បានផ្តល់ការអនុញ្ញាតហើយ ដោយសម្របសម្រួលការងារជាមួយគ្នា តាមរយៈយន្តការ «ច្រកចេញចូលតែមួយ» ។

**មាត្រា ២១** : ក្នុងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ច ដូចតទៅ÷

១- បំពេញតួនាទីជាយន្តការ «ច្រកចេញចូលតែមួយ» និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ

និងសម្រេចលើសំណើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងតាមរូបភាព រដ្ឋ ឯកជនចម្រុះរដ្ឋ និង ឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ធ្វើការវិភាគ លើកផែនការយុទ្ធសាស្ត្រដើម្បីកំណត់ពីភូមិសាស្ត្រសំខាន់ៗ ដោយសហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីបង្កើតនូវតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេស និងលើកឡើង នូវទស្សនៈអនាគតអំពីកិច្ចការតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ទាក់ទាញអ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ និងសម្រេចអោយបាននូវទស្សនៈនេះ ដោយធ្វើអោយប្រទេសកម្ពុជាក្លាយទៅជាតំបន់សាជីវកម្មទំនើបនាពេលអនាគត ។

៣-ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគតំបន់សេដ្ឋកិច្ចពិសេស ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅអោយអ្នកអភិវឌ្ឍន៍តំបន់តាមគ្រប់ប្រព័ន្ធឃោសនានានា ដែលមានប្រសិទ្ធភាព និងឆាប់រហ័ស ។

៤- ផ្តួចផ្តើម និងសម្របសម្រួលការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល ។

៥- លើកគម្រោងនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីអំពីការរៀបចំ និងការកែលំអច្បាប់ បទប្បញ្ញត្តិនានា និង ដែលទាក់ទិននឹងការវិនិយោគតំបន់សេដ្ឋកិច្ចពិសេសក្នុងគោលបំណងបង្កើតល័ក្ខខ័ណ្ឌ ដែលអនុគ្រោះ និង ដែលលើកទឹកចិត្តដល់អ្នកអភិវឌ្ឍន៍តំបន់ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគ ។

៦- ចាត់តាំងការគ្រប់គ្រង ផ្តល់ការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ការដោះស្រាយសំណូមពរ នានា និង កាធ្វើអធិការកិច្ច ចំពោះតំបន់សេដ្ឋកិច្ចពិសេស ។

៧- ចាត់បញ្ជូនមន្ត្រីដើម្បីចូលរួមប្រចាំការអចិន្ត្រៃយ៍នៅតាមតំបន់តាមការចាំបាច់ និងតាមតម្រូវការ ។

៨- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលំអបរិស្ថានវិនិយោគនៃតំបន់សេដ្ឋកិច្ចពិសេស និងតម្រង់ទិសការងារវិនិយោគតំបន់ ។

**មាត្រា ២២:** ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជាក្នុងការគ្រប់គ្រងកិច្ចការតំបន់សេដ្ឋកិច្ចពិសេសដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាលត្រូវកំណត់ដូចតទៅ÷

១- «ក.អ.ក » បំពេញតួនាទីជា «ច្រកចេញចូលតែមួយ » របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និង សម្រេចចុះបញ្ជីលើសំណើបង្កើតតំបន់សេដ្ឋកិច្ចពិសេស ។

២- ក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស ក្នុងក្របខ័ណ្ឌនៃយន្តការ «ច្រកចេញចូលតែមួយ» ។

៣- សហការជាមួយក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធដើម្បីរៀបចំបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ច ពិសេស ប្រចាំតំបន់នីមួយៗ និងណែនាំការចេញលិខិតអនុញ្ញាតនានារបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ជូនដល់អ្នកវិនិយោគក្នុងតំបន់នៅនឹងកន្លែងនៃតំបន់នីមួយៗ ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព ។

# ជំពូកទី ៣
# ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា ២៣ :** សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ:

១- ទទួលខុសត្រូវរួមលើការងាររបស់ «ក.អ.ក»

២- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៣- ដឹកនាំពិភាក្សា និង ថែរក្សាសណ្ដាប់ធ្នាប់ នៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និង អង្គប្រជុំពេញអង្គ «ក.អ.ក» ។

៤- ចុះហត្ថលេខាលើកំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និង អង្គប្រជុំពេញអង្គរបស់ « ក.អ.ក» ។

៥- កោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក» និង ប្រជុំវិសាមញ្ញពេញអង្គរបស់ «ក.អ.ក» ។

៦- ទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិការបស់ «ក.អ.ក» ។

**មាត្រា ២៤ :** នាយករដ្ឋមន្ត្រីដឹកនាំផ្ទាល់នូវការលើក និងការកំណត់គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស និង នូវការអនុវត្ត និងតាមដានគោលនយោបាយ និងយុទ្ធសាស្ត្រនេះ ។

**មាត្រា ២៥ :** អនុប្រធាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ:

**ក.** ឯកឧត្តម គាត ឈន់ អនុប្រធានទី១ ÷

១- ទទួលខុសត្រូវរួមលើការងាររបស់«ក.អ.ក»ក្នុងករណីដែលសហប្រធាន «ក.អ.ក» អវត្ត មាន ។

២- ទទួលបន្ទុកលើក និងស្នើគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជារួម ។

៣- ទទួលបន្ទុកការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ដែលផ្ដោតជាសំខាន់ទៅលើការសម្របសម្រួលលើកិច្ចការវិនិយោគសាធារណៈ និងកិច្ចការកៀរគរ និងសម្របសម្រួលជំនួយបរទេស ។

៤- ទទួលខុសត្រូវក្នុងការដឹកនាំ និង គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ «ក.អ.ក» ។

៥- ធ្វើជាអធិបតី នៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ«ក.អ.ក » និង អង្គប្រជុំពេញអង្គ របស់ «ក.អ.ក » និង ចុះហត្ថលេខាលើកំណត់ហេតុនៃអង្គប្រជុំនោះ ក្នុងករណីដែលសហ ប្រធាន «ក.អ.ក» អវត្តមាន ។

៦- ទទួលបន្ទុកក្នុងការសម្របសម្រួលការងារអន្តរក្រសួងរវាង «ក.អ.ក » ជាមួយនឹងក្រសួង ស្ថាប័ន នានា នៃរាជរដ្ឋាភិបាល ។

៧- ទទួលបន្ទុកក្នុងការទាក់ទងជាមួយប្រទេស និង អង្គការអន្តរជាតិអ្នកផ្តល់ជំនួយនានា។

៨- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដែលរៀបចំឡើងដោយ «ក.អ.ក» ដើម្បីពិនិត្យឯកភាពក្នុងយន្តការ«ច្រកចេញចូលតែមួយ» លើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងលើការវិនិយោគនានា មុននឹងដាក់ស្នើសុំសេចក្តីសម្រេចពីអង្គប្រជុំគណៈកម្មាធិ ការប្រតិបត្តិនៃ «ក.អ.ក» ។

៩- បំពេញការងារដទៃទៀតដែលសហប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

**ខ-** ឯកឧត្តម ចម ប្រសិទ្ធ អនុប្រធាន÷

១- ទទួលខុសត្រូវរួមលើការងាររបស់ «ក.អ.ក »ក្នុងករណីដែលសហប្រធាន និង អនុប្រធានទី ១ នៃ «ក.អ.ក» អវត្តមាន ។

២- ទទួលបន្ទុកលើក និង ស្នើគោលនយោបាយ និង យុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម និងវិនិយោគ ឯកជន និង កិច្ចការដឹកនាំ អនុវត្ត និងតាមដានការអនុវត្តនីគោលនយោបាយ និង យុទ្ធសាស្ត្រនេះ។

៣- ទទួលបន្ទុកកិច្ចការវិនិយោគផ្សេងៗ នៅក្នុងក្របខ័ណ្ឌអាស៊ាន ដែលជាប្រការស្របគ្នាទៅនឹងការ រៀបចំរបស់អាស៊ាន ។

៤- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដែលរៀបចំឡើងដោយ «ក.អ.ក» ដើម្បីពិនិត្យឯកភាពក្នុងយន្តការ «ច្រកចេញចូលតែមួយ» លើការងារវិនិយោគឯកជន។

៥- ទទួលបន្ទុកពិនិត្យ និងសំរេចលើគំរោងវិនិយោគឯកជន ដែលមានលក្ខណៈសាមញ្ញ ដូចជា រោងចក្រកាត់ដេរ-រោងចក្រស្បែកជើង-ឧស្សាហកម្មគាំទ្រ-សណ្ឋាគារជាដើម និងគំរោងដែល សម្តេចនាយករដ្ឋមន្ត្រីបានសំរេចរួចហើយ ព្រមទាំងបណ្តាគំរោង ដែលមិនទាមទារការលើកទឹក ចិត្តផងដែរ ។

៦- បំពេញការងារដទៃទៀត ដែលសហប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

គ. ឯកឧត្តម គង់ វិបុល អនុប្រធាន÷

១- ទទួលខុសត្រូវរួមលើការងាររបស់ «ក.អ.ក» ក្នុងករណីដែលសហប្រធាន និងអនុប្រធានទាំងពីររូបនៃ «ក.អ.ក» អវត្តមាន។

២- ទទួលបន្ទុកការងារប្រចាំរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ។

៣- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ«ច្រកចេញចូលតែមួយ» ដែលរៀបចំដោយ «ក.អ.ក» ដើម្បីពិនិត្យឯកភាពក្នុងយន្តការ «ច្រកចេញចូលតែមួយ» លើការងារវិនិយោគឯកជន ក្នុងករណីឯកឧត្តម ចម ប្រសិទ្ធ អវត្តមាន ឬ ជាប់រវល់ ដោយប្រការណាមួយ ។

៤- ទទួលការងារនៃតំបន់វិនិយោគអាស៊ាន (AIA)ដោយសម្របសម្រួលជាមួយអនុប្រធានពីររូបទៀត។

៥- ទទួលខុសត្រូវលើការងាររបស់ «ក.អ.ក »ក្នុងករណីដែលសហប្រធាន និងអនុប្រធានពីររូបទៀត នៃ «ក.អ.ក» អវត្តមាន ។

៦- បំពេញការងារដទៃទៀតដែលសហប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ។

**មាត្រា ២៦ :** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ ÷

១- ទទួលបន្ទុកក្នុងការសម្របសម្រួល និង តាមដានការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ការងាររបស់គណៈកម្មាធិការវិនិយោគកម្ពុជា និងការងាររបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ព្រមទាំងគ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាន នៃ «ក.អ.ក» ។

២- ធ្វើជាសេនាធិការបច្ចេកទេសអោយ «ក.អ.ក » ក្នុងការដឹកនាំអនុវត្ត និង តាមដានការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រ ពាណិជ្ជកម្ម ឧស្សាហកម្ម វិនិយោគឯកជន និងការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស។

៣- រៀបចំកម្មវិធីការងាររបស់ «ក.អ.ក»និងរៀបចំរបៀបវារៈ និង សំណុំឯកសារផ្សេងៗសម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៤- រៀបចំកំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» អង្គប្រជុំពេញអង្គ របស់ «ក.អ.ក» ដើម្បីដាក់ជូនប្រធានអង្គប្រជុំចុះហត្ថលេខា ។

៥- រៀបចំសេចក្តីប្រកាសពត៌មានរបស់ «ក.អ.ក» ។

៦- ជួយសម្របសម្រួលការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីការងារនីតិសម្បទា និងអភិវឌ្ឍន៍ ការងារវិនិយោគឯកជន និងការងារតំបន់សេដ្ឋកិច្ចពិសេសដើម្បីដាក់ជូន «ក.អ.ក» ពិនិត្យ និងអនុម័តមុននឹងផ្ញើ ជូនរាជរដ្ឋាភិបាល ។

៧- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ការវិនិយោគនានា និងការងារតំបន់សេដ្ឋកិច្ចពិសេស ។

៨- បំពេញការងារដទៃទៀត ដែលសហប្រធាន «ក.អ.ក» ឬអនុប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

៩- ទទួលបន្ទុកជាអគ្គលេខាធិការនៃវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន ។

**មាត្រា ២៧ :** អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ ៖

១- គ្រប់គ្រងការងាររបស់ «គ.ជ.នា» ។

២- រៀបចំរបៀបវារៈនិងឯកសារសម្រាប់អង្គប្រជុំនៃយន្តការ «ច្រកចេញចូលតែមួយ» ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ។

៣- ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងសម្រាប់អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៤- ធ្វើការតាមដានលើការអនុវត្តកម្មវិធីនិងគម្រោងវិនិយោគសាធារណៈផ្សេងៗ ដោយសហការជាមួយបណ្ដាក្រសួង និងស្ថាប័នជំនាញ ដែលពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ដើម្បីពិនិត្យ និងចាត់វិធានការណ៍កែតម្រូវក្នុងករណីចាំបាច់ ។

៥- ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដើម្បីដាក់ជូន «ក.អ.ក» ពិនិត្យ និងអនុម័ត មុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ។

៧- បំពេញការងារដទៃទៀត ដែលទាក់ទិនទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ស្របតាមការប្រគល់ភារកិច្ចពីប្រធាន «ក.អ.ក» ឬអនុប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

**មាត្រា ២៨ :** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានតួនាទីដូចតទៅ ៖

១-គ្រប់គ្រងការងាររបស់ « គ.វ.ក »

២-រៀបចំរបៀបវារៈនិងឯកសារសម្រាប់អង្គប្រជុំយន្តការ «ច្រកចេញចូលតែមួយ» ដែលមានការទាក់ទងទៅនឹងកិច្ចការវិនិយោគឯកជន ។

៣-ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិនទៅ

នឹងកិច្ចការវិនិយោគឯកជន សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និង សម្រាប់អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៤-ធ្វើការតាមដានលើការអនុវត្តកម្មវិធីនិងគម្រោងវិនិយោគឯកជនផ្សេងៗ ដោយសហការជាមួយ បណ្តាក្រសួង និង ស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និង លើក យោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ដើម្បីពិនិត្យ និង ចាត់វិធានការណ៍កែតម្រូវ ក្នុងករណីចាំបាច់ ។

៥-ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែក ការងារពាក់ព័ន្ធទៅនឹងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូន «ក.អ.ក» ពិនិត្យ និង អនុម័ត មុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៦-ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និង សម្រេចលើកិច្ចការ វិនិយោគឯកជន ។

៧-បំពេញការងារដទៃទៀត ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន ស្របតាមការប្រគល់ ភារកិច្ចពីសហប្រធាន ឬអនុប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

**មាត្រា ២៩ :** អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានតួនាទីដូចតទៅ ៖

១- គ្រប់គ្រងការងាររបស់ « គ.ស.ព »

២- រៀបចំរបៀបវារៈនិងឯកសារសម្រាប់អង្គប្រជុំយន្តការ «ច្រកចេញចូលតែមួយ» ដែលមានការ ទាក់ទងទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ។

៣- ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិន ទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៤- ធ្វើការតាមដានលើការអនុវត្តកម្មវិធីនិងការវិវឌ្ឍន៍នៃគម្រោងតំបន់ សេដ្ឋកិច្ចពិសេសនានាដោយ សហការជាមួយ បណ្តាក្រសួង និងស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍ បូកសរុបនិងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ដើម្បីពិនិត្យ និងចាត់ វិធានការណ៍កែតម្រូវក្នុងករណីចាំបាច់ ។

៥- ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើ ផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដាក់ជូន «ក.អ.ក» ពិនិត្យ និងអនុម័ត មុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការ តំបន់សេដ្ឋកិច្ចពិសេស ។

៧- បំពេញការងារដទៃទៀតដែលទាក់ទងទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ស្របតាមការប្រគល់ភារកិច្ចពីសហប្រធាន ឬអនុប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ។

**មាត្រា ៣០ :** សមាជិកនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ ៖

១- ចូលរួមក្នុងការកំណត់ទស្សនទាន និងគោលនយោបាយនៃកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ គម្រោងកិច្ចការវិនិយោគឯកជន និងគម្រោងតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងចូលរួមក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី គម្រោងវិនិយោគនានា និងគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងផ្នែកសាធារណៈ និងទាំងផ្នែកឯកជន។

២- ចូលរួមក្នុងការត្រួតពិនិត្យ ការអនុវត្តគោលនយោបាយកម្មវិធីគម្រោងវិនិយោគនានា និងគម្រោងតំបន់សេដ្ឋកិច្ចពិសេស ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តទាំងខាងផ្នែកសាធារណៈ ទាំងខាងផ្នែកឯកជន និងទាំងខាងផ្នែកតំបន់សេដ្ឋកិច្ចពិសេស។

៣- ពិនិត្យ និងអនុម័ត របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍កិច្ចការវិនិយោគឯកជន កិច្ចការតំបន់សេដ្ឋកិច្ចពិសេស មុននឹងផ្ញើជូនរាជរដ្ឋាភិបាលពិនិត្យ និង សម្រេច។

**មាត្រា ៣១ :** គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ត្រូវអញ្ជើញចូលរួមប្រជុំក្នុងពីរអាទិត្យម្តង។

**មាត្រា ៣២ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកោះប្រជុំពេញអង្គក្នុងមួយខែម្តង។

**មាត្រា ៣៣ :** ក្នុងករណីចាំបាច់ សហប្រធាន «ក.អ.ក» អាចនឹងកោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ឬប្រជុំវិសាមញ្ញពេញអង្គរបស់ «ក.អ.ក» ។

**មាត្រា ៣៤ :** ការប្រព្រឹត្តិទៅនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងអង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃ «ក.អ.ក» ។

**មាត្រា ៣៥ :** ការអនុវត្តការងារនៃយន្តការ «ច្រកចេញចូលតែមួយ» របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការពិនិត្យលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ លើការវិនិយោគនានា និងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ត្រូវរៀបចំឡើងតាមរបៀបរបប ជាគោលការណ៍ ដូចខាងក្រោម ៖

**ទី១**- សម្រាប់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ៖

ក- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាននាយកដ្ឋានមួយរូប អោយមកអមគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។

មន្ត្រីរូបនោះត្រូវ ÷

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន។
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមួត ក្នុងការទាក់ទងជាមួយប្រធានស្ថាប័ន របស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន។
- ស្ថិតរមួតក្នុងការងារ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួងនិងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ «ច្រកចេញចូលតែមួយ» នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ «អែដហុក» តាមការអញ្ជើញរបស់អគ្គលេខាធិការ «គ.ជ.នា» ចំពោះតែកិច្ចការវិនិយោគសាធារណៈណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង ស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ « គ.ជ.នា » មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងឯកភាពក្នុងអង្គប្រជុំនៃស្ថាប័ន «ច្រកចេញចូលតែមួយ» ដល់តំណាងក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុតាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ-ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តុំឯកសារចាំបាច់នានាបានចប់សព្វគ្រប់ តាមបែបបទជាធរមាន ហើយអគ្គលេខាធិការ « គ.ជ.នា » ត្រូវរៀបចំបញ្ចូលកម្មវិធី ឬ គម្រោងនោះ ទៅក្នុងអង្គប្រជុំនៃ យន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ « គ.ជ.នា» ត្រូវរៀបចំសំណុំឯកសារ និងពត៌មានផ្សេងៗ ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» បញ្ជូនទៅអគ្គលេខាធិការ «ក.អ.ក» ដើម្បីរៀបចំដាក់ជូនអង្គប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ «ក.អ.ក» ពិនិត្យ និងសម្រេច។

**ទី២**- សម្រាប់គណៈកម្មាធិការវិនិយោគកម្ពុជា ÷

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួងផែនការ និងក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាននាយកដ្ឋានមួយរូបអោយមកអមគណៈកម្មាធិការវិនិយោគកម្ពុជា។

មន្ត្រីរូបនោះត្រូវ ÷

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន។

- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្និតរមួតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន ។
- ស្និតរមួតក្នុងការងារ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការវិនិយោគកម្ពុជា ។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស ។

ខ- ក្រសួង និងស្ថាប័នដទៃ ទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ «ច្រកចេញចូលតែមួយ »នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ «អែដហុក » តាមការអញ្ជើញរបស់អគ្គលេខា ធិការ « គ.វ.ក » ចំពោះតែកិច្ចការវិនិយោគឯកជនណា ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួងស្ថាប័នទាំងនោះ ។

គ- អគ្គលេខាធិការ « គ.វ.ក » មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងសម្រេចក្នុងអង្គប្រជុំនៃ យន្តការ «ច្រកចេញចូលតែមួយ » ដល់តំណាងក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រី ដែលជាតំណាងរបស់ខ្លួន ។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានា បានចប់សព្វគ្រប់តាមបែបបទជាធរមានហើយ អគ្គលេខាធិការ « គ.វ.ក. » ត្រូវរៀបចំបញ្ចូលកម្មវិធី ឬ គម្រោងនោះ ទៅក្នុងអង្គប្រជុំនៃយន្តការ «ច្រកចេញចូលតែមួយ » ដើម្បីពិនិត្យ និងសម្រេច ។

ង- អគ្គលេខាធិការ « គ.វ.ក. » ត្រូវរៀបចំសំណុំឯកសារ និងពតិមានផ្សេងៗ ដែលជាលទ្ធផល នៃកិច្ចប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ » បញ្ជូនទៅអគ្គលេខាធិការ « ក.អ.ក » ដើម្បីពិនិត្យ និងសម្រេច ។

**ទី៣**- សម្រាប់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ÷

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ត្រូវចាត់មន្ត្រីរបស់ខ្លួនថ្នាក់ប្រធាននាយកដ្ឋានមួយរូបអោយមកអមគណៈកម្មាធិការតំបន់សេដ្ឋកិច្ចកម្ពុជា ។

មន្ត្រីរូបនោះត្រូវ ÷

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន ។
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្និតរមួតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន ។
- ស្និតរមួតក្នុងការងារ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស ។

ខ- ក្រសួង និងស្ថាប័នដទៃ ទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ «ច្រកចេញចូលតែមួយ»នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ «អែដហុក» តាមការអញ្ជើញរបស់អគ្គលេខា ធិការ « គ.ស.ព »ចំពោះតែកិច្ចការតំបន់សេដ្ឋកិច្ចពិសេសណា ដែលពាក់ព័ន្ធទៅនឹងសម្ថកិច្ចនៃក្រសួង ស្ថាប័ន ទាំងនោះ។

គ- អគ្គលេខាធិការ « គ.ស.ព » មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និង សម្រេចក្នុងអង្គប្រជុំនៃ យន្តការ «ច្រកចេញចូលតែមួយ» ដល់តំណាងក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រី ដែលជាតំណាងរបស់ខ្លួន។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានា បានចប់សព្វគ្រប់តាមបែបបទជាធរមានហើយ អគ្គលេខាធិការ « គ.ស.ព » ត្រូវរៀបចំបញ្ចូលកម្មវិធី ឬ គម្រោងនោះ ទៅក្នុងអង្គប្រជុំនៃ យន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ « គ.ស.ព » ត្រូវរៀបចំសំណុំឯកសារ និងពតិមានផ្សេងៗ ដែលជាលទ្ធផល នៃកិច្ចប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» បញ្ជូនទៅអគ្គលេខាធិការ «ក.អ.ក» ដើម្បីពិនិត្យ និង សម្រេច។

**ទី៤-** ក្រោយពីទទួលបានគ្រប់គ្រាន់នូវឯកសារ និងពតិមានផ្សេងៗពី អគ្គលេខាធិការ « គ.ជ.នា » អគ្គលេខាធិការ « គ.វ.ក. » អគ្គលេខាធិការ « គ.ស.ព » មក អគ្គលេខាធិការ «ក.អ.ក » ត្រូវរៀបចំសំណុំឯកសារទាំងអស់នោះតាមលំដាប់ ហើយដាក់ចូលក្នុងរបៀបវារៈនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ « ក.អ.ក » ដើម្បីពិនិត្យ និងសម្រេច។

**មាត្រា ៣៦** : សេចក្តីលំអិតអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័ន «ច្រកចេញចូលតែមួយ»របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ« ក.អ.ក»។

**មាត្រា ៣៧** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានក្របខ័ណ្ឌមន្ត្រីរាជការ និង មានខ្ទង់ចំណូល និងចំណាយថវិការបស់ខ្លួន ។ ការគ្រប់គ្រងចំណូល និងចំណាយថវិកា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ៣៨** : អនុក្រឹត្យលេខ ៧០ អនក្រ បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ អនុក្រឹត្យ លេខ ១១២ អនក្រ បក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ និង អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣៩** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលគ្រប់ខេត្ត-ក្រុង ពាក់ព័ន្ធទាំងអស់ និង សមាសភាពនានាដូចមានក្នុងមាត្រា ១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គាត ឈន់**

***កន្លែងទទួល:***

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ៣៩
-ឯកសារ-កាលប្បវត្តិ